# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងសម្របសម្រួលកិច្ចការ ពាក់ព័ន្ធនឹងការវិនិយោគរបស់ក្រុមហ៊ុន Samling Strategic Corporation Sdn Bhd

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .—**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងការវិនិយោគរបស់ក្រុមហ៊ុន Samling Strategic Corporation Sdn Bhd ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **ស៊ុន ចាន់ថុល** | ឧបនាយករដ្ឋមន្ត្រី<br>អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | ប្រធាន |
| ២- ឯកឧត្តម **សាយ សំអាល់** | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | អនុប្រធាន |
| ៣- ឯកឧត្តម **ឌិត ទីណា** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៤- ឯកឧត្តម **អ៊ាង សុផល្លែត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | សមាជិក |
| ៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | | ១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | | ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | | ១រូប | សមាជិក |
| ៩- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | | | សមាជិក |
| ១០- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | សមាជិក |

១១- តំណាងអគ្គនាយកដ្ឋានពន្ធដារ ១រូប សមាជិក
១២- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប សមាជិក
១៣- តំណាងរដ្ឋបាលព្រៃឈើ ១រូប សមាជិក។

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួងនេះមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំពិនិត្យលើការអនុវត្តគម្រោងវិនិយោគរបស់ក្រុមហ៊ុន Samling Strategic Corporation Sdn Bhd និងសម្របសម្រួលលើកិច្ចការដោះស្រាយបណ្ដឹងដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនិងវឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិក នៃក្រុមការងារអន្តរក្រសួងនេះ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ដឹកនាំកិច្ចប្រជុំជំនួសបាន។

**ប្រការ៤ .-**

ក្រុមការងារនេះ មានសិទ្ធិអញ្ជើញអតីតថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃក្រសួង ស្ថាប័ននានា ដើម្បីផ្តល់យោបល់លើការងារដែលពាក់ព័ន្ធនឹងគម្រោងរបស់ក្រុមហ៊ុននិងកម្មវត្ថុនៃបណ្តឹង។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ